សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណ ហុក-សាវណ្ណ
## ក្រោមប្រធានបទ ទស្សនៈរបស់លោករូស្ស៊ សង្គមវិទូបស្ចឹមប្រទេស ប្រៀបមកពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ ។

www.hoksavann.org

ថ្ងៃទី២២ កក្កដា ២០១២



លោករូស្ស៊ូ ជាសង្គមវិទូម្នាក់នៅបស្ចឹមប្រទេសក្នុងសតវត្សរ៍ទី១៨បាននិយាយថា តាមធម្មជាតិ មនុស្សកើតមកល្អទេ តែដែលឲ្យមនុស្សទៅជាអាក្រក់ ដោយការអប់រំក្នុងសង្គម គឺគាត់និយាយថា មនុស្សកើតមកល្អទាំងអស់ តែសង្គមទេដែលបង្រៀនឲ្យអាក្រក់ ។ សេចក្តីពិត ការបញ្ចេញគំនិត ទស្សនៈ ទ្រឹស្តីនៃទស្សនវិទូនីមួយៗ តែងស្របទៅតាមចំណេះវិជ្ជាការពិសោធន៍ក្នុងការរស់នៅរបស់ខ្លួន ។ ក្នុងន័យនេះហើយ បានជាអ្នកសិក្សាទស្សនវិជ្ជាដំ-បូងគេសិក្សាអំពីជីវប្រវត្តិរបស់ទស្សនវិទូនោះសិន តមកទើបគេចាប់សិក្សាអំពីទស្សនវិជ្ជាដែលជាទ្រឹស្តីរបស់ទស្សនវិទូនោះជាក្រោយ ព្រោះថា បើគេបានសិក្សាអំពីជីវប្រវត្តិរបស់ទស្សនវិទូនោះ គេអាចយល់បានមួយភាគនូវទ្រឹស្តីរបស់គាត់ ដោយហេតុថា អ្នកទស្សនវិទូច្រើននិយាយឬសរសេរស្របតាមដំណើរជីវិតរបស់ខ្លួននៅក្នុងសង្គម ។ យ៉ាងណាមិញ លោករូស្ស៊ូជាជនសាមញ្ញនៅមានកិលេសតណ្ហា គាត់រស់នៅធ្លាប់ជួបប្រទះនឹងសេចក្តីទុក្ខលំបាកនៅក្នុងសង្គម មានត្រូវគេធ្វើបាបជាដើម លុះគាត់បញ្ចេញទ្រឹស្តីក៏តិះដៀលសង្គមទៅ ។

ចំពោះព្រះពុទ្ធជាម្ចាស់ ជាអ្នកបង្កើតព្រះពុទ្ធសាសនាវិញ តាំងពីព្រះអង្គចាប់ផ្តើមកសាងបារមីធម៌រហូតបានត្រាស់ជាព្រះពុទ្ធ ព្រះអង្គក៏បានទទួលសេចក្តីទុក្ខវេទនាដ៏ខ្លាំងក្លានៅក្នុងសង្គម ប៉ុន្តែពេលត្រាស់ដឹង ព្រះអង្គពុំដែលសំដែងពាក្យណាមួយដែលមានន័យតិះដៀល ឬបៀតបៀនសង្គមមនុស្សឡើយ ។ បានសេចក្តីថា ព្រះអង្គសំដែងធម៌ទៅតាមការពិតដែលព្រះអង្គត្រាស់ដឹង ពុំមែនសំដែងស្របតាមការឈឺចាប់ដូចទស្សនវិទូឡើយ ។ ពេលត្រាស់ដឹង ទោះបីមានមនុស្សខ្លះក្នុងសង្គមខំព្យាយាមបៀតបៀនព្រះអង្គក៏ដោយ ដូចពួកនិគ្រន្ថ ក៏ព្រះអង្គមានព្រះទ័យស្ងប់ជានិច្ច ។

ទស្សនៈលោករូស្ស៊ូថា មនុស្សកើតមកល្អទេ តែសង្គមទេដែលបង្រៀនឲ្យអាក្រក់ ។ចុះបើគេយកមនុស្សដែលកើតឡើងភ្លាមឲ្យទៅនៅដាច់ដោយឡែកពីសង្គមមនុស្ស តើមនុស្សនោះមានលក្ខណៈទៅជាយ៉ាងណាទៅវិញ ។ ប្រសិនបើមនុស្សកើតមកល្អទាំងអស់ វានៅតែល្អដដែល ទោះបីគេយកឲ្យទៅនៅរួមជាមួយអ្វីក៏ដោយ ។ ដូច្នេះទស្សនៈរបស់លោករូស្ស៊ូពុំត្រឹមត្រូវទាំងអស់ឡើយ ដោយគេសង្កេតឃើញថា មនុស្សព្រៃដែលរស់នៅក្នុងព្រៃ រស់នៅក្នុងសង្គមសត្វ តែងធ្វើតាមចរិយារបស់សត្វខ្លះ ហើយពុំមានអារ្យធម៌ខ្ពស់ ដូចជារស់នៅជាមួយសង្គមមនុស្សឡើយ ។ តាមព្រះពុទ្ធសាសនាសំដែងថា មនុស្សមានលក្ខណៈយ៉ាងណាអាស្រ័យកត្តាពីរយ៉ាង គឺនិស្ស័យវាសនាពីមុន និងការអប់រំក្នុងបច្ចុប្បន្ន ។ សេចក្តីពិត សង្គមមនុស្សពុំមែនអាក្រក់ដូចលោករូស្ស៊ូយល់នោះឡើយ មានអាក្រក់ខ្លះសម័យបុព្វកាល ដោយមេកន្ទ្រាញដណ្តើមការត្រួតត្រា ដោយប្រើកម្លាំងបាយ មិនប្រើសីលធម៌ និងការគោរពសិទ្ធិមនុស្សឡើយ ។ ដោយមនុស្សជាសត្វមានបញ្ញា ដឹងខុសត្រូវ ស្គាល់គុណទោស បើគេអប់រំខាងផ្លូវល្អ មនុស្សមានគុណធម៌កាន់តែខ្ពស់ឡើង ។ ទស្សនៈតិះដៀលសង្គមរបស់លោករូស្ស៊ូនេះហើយ ដែលថ្ងៃក្រោយកើតជាលទ្ធិកុម្មុយនិស្តផ្តាច់ការ សម្លាប់មនុស្សរាប់លាននាក់ ដែលយល់ខុសថា ដើម្បីសំអាតសង្គមឲ្យបានល្អ ។ ឆ្លងតាមការពិសោធន៍ សង្គមមនុស្សបច្ចុប្បន្នបានចំរើនលូតលាស់អស្ចារ្យ ទាំងផ្នែកសម្ភារៈនិងផ្នែកសីលធម៌ ។ ជាមួយគ្នានេះ ការដឹកនាំរដ្ឋក៏បានចំរើនលូតលាស់ ដោយកាន់របបប្រជាធិបតេយ្យសេរី និងការគោរពសិទ្ធិមនុស្សដោយធម្មនុញ្ញនៃអង្គការសហប្រជាជាតិបានចេញសេចក្តីប្រកាស ។

វិទ្យាសាស្ត្រខាងចិត្តវិទ្យានិយាយថា មនុស្សបានចម្លងតាមចរិតពីឪពុកម្តាយខ្លះ ពីសង្គមខាងក្រៅខ្លះ ខាងផ្នែករូបនិងផ្នែកចរិយា ។ ក្នុងន័យនេះ យើងគួរសង្កេតថា ចុះកូនកើតមកមានឪពុកម្តាយជាមួយគ្នា អប់រំគ្រូជាមួយគ្នា រស់នៅក្នុងសង្គមជាមួយគ្នា ហេតុអ្វីបានជាកូនមានចរិតលក្ខណៈផ្សេងគ្នា ? ។ បញ្ហានេះ ចំពោះវិទ្យាសាស្ត្រខាងចិត្តវិទ្យានិយាយពុំច្បាស់លាស់ឡើយ ។ ព្រះពុទ្ធសាសនាទើបនិយាយច្បាស់លាស់ កូនដែលមានចរិតលក្ខណៈផ្សេងគ្នានេះ ដោយសារនិស្ស័យពីមុន និងការអប់រំក្នុងបច្ចុប្បន្ន ។ ត្រង់ន័យនេះបញ្ជាក់ថា លោករូស្ស៊ូក្តី អ្នកចិត្តវិទូក្តី ជាមនុស្សបុថុជ្ជនពុំអាចមានទស្សនៈត្រឹមត្រូវដូចជាព្រះពុទ្ធអង្គ ដែលមានព្រះទ័យបរិសុទ្ធនិងព្រះបញ្ញាញាណដ៏ជ្រៅឡើយ ។

(នៅមានត)